# ប្រាសាទភូមិប្រាសាទ

ប្រាសាទភូមិប្រាសាទ មានទីតាំងស្ថិតនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចម្ងាយប្រមាណ ២៨គ.ម. ខាងត្បូងទីរួមខេត្តកំពង់ធំ។ ការដែលហៅថា "ភូមិប្រាសាទ" មកដូច្នេះ ទំនងមកពីអ្នកស្រុកភ្លេច ឬមិនដឹងថាឈ្មោះដើមប្រាសាទនេះថាដូចម្តេច ក៏ហៅថា "ប្រាសាទ" តែម្តងទៅ។ កន្លងមកប្រាសាទនេះ មានអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិធ្លាប់សិក្សាច្រើនណាស់ ហើយការសិក្សាលម្អិតជាងគេនោះ គឺការសិក្សារបស់លោក ព្រាប ចាន់ម៉ារ៉ា និងសហការី ក្នុងឆ្នាំ២០០០ ដើម្បីបញ្ចប់សារណាថ្នាក់បរិញ្ញាបត្របុរាណវិទ្យា។

ប្រាសាទនេះកសាងឡើងអំពីឥដ្ឋ មានរាងបួនជ្រុងទ្រវែង បែរមុខទៅទិសខាងកើត អមដោយបដិមាតោពីរនៅឈរយាមខាងមុខ ហើយជាពិសេសនោះ ប្រាសាទនេះនៅមានរូបរាងល្អប្រសើរប្រកបដោយក្បាច់រចនាយ៉ាងរស់រវើក (រូបលេខ១-២)។ នៅឆ្នាំ១៩៤០ លោកស្រី Gilberte De Coral Rémusat បានចាត់ថ្នាក់ប្រាសាទនេះចូលទៅក្នុងរចនាបថកំពង់ព្រះ ដោយផ្តល់កាលបរិច្ឆេទរចនាបថកំពង់ព្រះនៅផ្នែកទី២នៃស.វ.ទី៨។[១] ក្រោយមក លោក Jean Boisselier បានកំណត់កាលបរិច្ឆេទរចនាបថកំពង់ព្រះសារជាថ្មី គឺចាប់ពីគ.ស.៧០៦ ដល់ ៨០០។ ការដែលលោកចាត់ថ្នាក់រចនាបថកំពង់ព្រះទាំងមូលចាប់ពីគ.ស.៧០៦នេះ គឺដោយសារលោកយោងទៅលើប្រាសាទភូមិប្រាសាទដែលមានសិលាចារឹកផ្តល់កាលបរិច្ឆេទឱ្យក្នុងគ.ស.៧០៦ រីឯប្រាសាទកំពង់ព្រះដែលគេកំណត់យកជាឈ្មោះរចនាបថនោះ ពុំមានសិលាចារឹកឱ្យយើងដឹងពត៌មានច្បាស់លាស់ឡើយ។[២]

ប្រាសាទនេះមានទ្វារចូលនៅខាងកើត និងពុំមានលម្អជាទ្វារបញ្ឆោតដូចប្រាសាទដទៃទៀតក្នុងរចនាបថមុនៗឡើយ ប៉ុន្តែគេលម្អជាជញ្ជាំងលាតទ្រដោយខឿនរាងជាសារពើសូត្រ។ នៅលើផ្ទៃជញ្ជាំងនីមួយៗគេរៀបជាក្បាច់រុក្ខជាតិត្រួតលើគ្នាយ៉ាងប្រណិតបំផុត។ ផ្តែរទ្វារវិញ នៅរក្សាទម្រង់ស្ទើរតែដូចដើម ដែលលម្អទៅដោយក្បាច់បន្ទាត់ធ្នូមានរាងដូចមែកឈើ ខាងចុងផ្តែរមានគួចទៅលើចូលក្នុងដូចគូទខ្យង នៅកណ្តាលជាក្បាច់សន្ទឹកមានរូបកិត្តិមុខ (ប្រែថា៖ មុខដែលមានយស មានសិរីសួស្តី មានកេរ្តិ៍ ហើយខ្មែរយើងនិយមហៅថា "រាហូ") ឬអាចជាព្រះកាល (ជាការបែងភាគរបស់ព្រះសិវជាតួអង្គដែលមានទឹកមុខកាចសាហាវ ហើយគេច្រើនយល់ថាជានិម្មិតរូប

[១] Coral Rémusat 1940.

[២] Boisselier 1966.

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

នៃសេចក្តីស្លាប់និងការកើតឡើងវិញ)[៣] (រូបលេខ៣)។ ការលម្អរូបកិត្តិមុខឬព្រះកាលនៅកណ្តាលផ្តែរបៀបនេះ មានភាពនិយមខ្លាំងណាស់នៅក្នុងរចនាបថកំពង់ព្រះ ដូចឃើញមាននៅប្រាសាទព្រៃក្មេង ផ្តែរមួយមកពីតំបន់សំបូរ-ក្រចេះ និងប្រាសាទភ្នំស្រួច។ ក្រៅអំពីផ្តែរដែលនៅរូបរាងល្អ សសរពេជ្រ និងសសរផ្តោបនៅប្រាសាទភូមិប្រាសាទ ក៏នៅតែរក្សារូបរាងល្អប្រសើរដូចគ្នា (រូបលេខ៤)។

រីឯនៅខាងក្នុងប្រាសាទវិញ សព្វថ្ងៃយើងឃើញជើងទម្រមួយទ្រូរូបបដិមាហរិហរ តែជារូបចម្លងថ្មីទេ ព្រោះរូបបដិមាដើមកំពុងរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ (រូបលេខ៥)។ ហរិហរ គឺជាការរួមបញ្ចូលគ្នារវាងអាទិទេពចំនួនពីរគឺព្រះវិស្ណុ និងព្រះឥសូរ ម៉្លោះហើយបដិមាដែលគេឆ្លាក់មកនេះត្រូវមានទម្រង់ជាព្រះវិស្ណុម្ខាង ព្រះឥសូរម្ខាង។ ក្នុងនោះដែរ រឿងហេតុដែលនាំឱ្យទេពទាំងពីររួមបញ្ចូលគ្នានេះ ក៏មានរៀបរាប់នៅក្នុងគម្ពីរវិស្ណុបុរាណ ដែលសង្ខេបមកថា៖ នៅពេលព្រះក្រឹស្ណបម្រុងសម្លាប់យក្សមួយឈ្មោះ បន ស្រាប់តែព្រះឥសូរមកជួយអន្តរាគមន៍ ដោយទ្រង់បានទូលអង្វរព្រះវិស្ណុកុំឱ្យសម្លាប់យក្សនេះអី ព្រោះយក្សនេះគឺជាកូនសិស្សសំណព្វរបស់ទ្រង់។ ពេលនោះ ព្រះវិស្ណុក៏យល់ព្រម តែទ្រង់បានដាក់លក្ខខណ្ឌឱ្យព្រះឥសូរប្រកាសប្រាប់ទៅលោកទាំងមូលថា ព្រះវិស្ណុក៏ជាអាទិទេពកំពូលដែរ ហើយគ្រានោះព្រះឥសូរក៏យល់ព្រមក៏កើតជាការបង្រួមនិងរួមបញ្ចូលរាងកាយនេះឡើងដោយឱ្យព្រះនាមថា "ហរិហរ" (មានគម្ពីរខ្លះទៀតនិទានរឿងផ្សេងពីនេះក៏មានដែរ)។[៤]

ចំណុចគួរកត់សម្គាល់សំខាន់នៃប្រាសាទភូមិប្រាសាទគឺ សិលាចារឹកដែលចារនៅលើមេទ្វារខាងកើតផ្នែកខាងជើង តែជារឿងចម្លែកដែរ ដែលសិលាចារឹកនេះគេចារនៅខាងក្រោមទៅវិញ ខុសពីសិលាចារឹកនានាគេនិយមចារពីលើមក។ សិលាចារឹកនេះ ចុះបញ្ជីលេខ K.145 មានចំនួន៥បន្ទាត់ ចារឹកជាភាសាខ្មែរបុរាណលាយជាមួយភាសាសំស្ក្រឹតខ្លះៗ ក្នុងមហាសករាជឆ្នាំ៦២៨ ត្រូវនឹងគ្រឹស្តសករាជឆ្នាំ ៧០៦ ដែលសេចក្តីទាំងមូលរៀបរាប់ថា៖ "ម.ស.៦២៨ ៣កើត ខែអាសាឍ ម្រតាញ្មេជាវិទ្ធ ប្រទានស្រែចំនួន ១ស៊្លឹក អ្នកបម្រើ៣នាក់ កឱិល អង្គរ...ដេ ទឹកដោះគោ ៤ គ្រឿងបូជាផ្សេងៗនេះផង..... សម្លៀកបំពាក់ ព្រះ...............លយេ ................នរកអវិចី"។[៥] សិលាចារឹកបានផ្តល់កាលបរិច្ឆេទឆ្នាំគ.ស.៧០៦ ប៉ុន្តែយើងមិនដឹងថាស្ថិតនៅក្នុងរជ្ជកាលស្តេចអង្គណានោះឡើយ ព្រោះទិន្នន័យសិលាចារឹកដែលសេសសល់សម្រាប់ធ្វើជាតឹកតាងក្នុងការ

[៣] Smitthi and Elizabeth 1992; Ang 2004; Saveros 1991.

[៤] Cornelia and Buitenen 1978.

[៥] Coedès 1954: 72.

*សិក្សាប្រវត្តិសាស្ត្រខ្មែរពុំគ្រប់គ្រាន់ឡើយ ពោល គឺចាប់ពីឆ្នាំ៦៨១ ដល់ ៧១៣ គេមិនដឹងថាមានព្រឹត្តិការណ៍អ្វីកើតឡើងនោះឡើយ។ ប៉ុន្តែ យើងអាចត្រឹមដឹងថា ឆ្នាំគ.ស.៧០៦ ស្ថិតនៅចន្លោះរជ្ជកាលស្តេចជ័យវរ្ម័នទី១* (គ.ស.៦៥៧ - ៦៨១) *និងរជ្ជកាលព្រះនាងជ័យទេវី*(គ.ស.៧១៣? ដល់ .....?)។

*ជារួមមក ប្រាសាទភូមិប្រាសាទ ជាប្រាសាទមួយស្ថិតនៅក្នុងរចនាបថកំពង់ព្រះ ក្នុងឆ្នាំ៧០៦ នៃគ្រឹស្តសករាជ តែយើងមិនដឹងប្រាកដពីរជ្ជកាលស្តេចអង្គណាមួយឡើយ។ ប្រាសាទនេះសាងឡើងឧទ្ទិសដល់ព្រហ្មញ្ញសាសនា តាមរយៈតឹកតាងបដិមាដែលតម្កល់នៅក្នុងប្រាសាទជាវិស្ណុមួយចំហៀង ឥសូរមួយចំហៀង ដែលគេច្រើនហៅថា "ហរិហរ" ឬ "ស្រីសង្ករនារាយណ៍"៕*

## ឯកសារយោង


**ព្រាប ចាន់ម៉ារ៉ា និងសហការី** (២០០០) *ភូមិប្រាសាទ ដំណែលបុរាណ និងកិច្ចប្រតិបត្តិ*, *សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា ជំនាន់ទី៧*, *ភ្នំពេញ*។

**Ang, C.** (2004) 'La mort-renaissance en abstraction iconographique, *UDAYA,* Numéro 5, Phnom Penh.

**Boisselier, J.** (1966) *Asie du Sud-Est, Le Cambodge,* Tome 1, part 1.

**Cornelia, D. and Buitenen, J.A.B.** (1978) *Classical Hindu Mythology*, USA.

**Coedès, G.** (1954) *Inscription du Cambodge,* Tome VI, Hanoi.

**De Coral Rémusat, G.** (1940) *L' Art Khmers, les grandes étapes et son evolution, les éditions d'art et d'histoire*, Paris.

**Saveros, P.** (1992) *Dictionaire Vieux Khmer-Français-Englais*, Paris.

**Smitthi, S. and Elizabeth, M.** (1992) *Palace of the gods*, Asia Book, Bangkok.


*អត្ថបទដោយ៖ ម៉ង់ រ៉ាលី*



រូបលេខ១៖ ប្រាសាទភូមិប្រាសាទ (មុខខាងកើត)

អត្ថបទដោយៈ ម៉ង់ រ៉ាលី



រូបលេខ២៖ ប្រាសាទភូមិប្រាសាទ (មុខខាងលិច)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៖ ផ្តែរទ្វារប្រាសាទភូមិប្រាសាទ



រូបលេខ៤៖ សសរពេជ្រនិងសសរផ្តោបប្រាសាទភូមិប្រាសាទ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ បដិមាព្រះហរិហររកឃើញនៅប្រាសាទភូមិប្រាសាទ (រូបថត៖ ព្រាប ចាន់ម៉ារ៉ា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី